ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មន្ទីរកសិកម្ម ខេត្តតាកែវ
លេខ.........មកសិ

តាកែវ, ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១៦

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

**កម្មវត្ថុ:** របាយការណ៍សង្ខេបស្តីពីលទ្ធផលការងារកសិកម្មប្រចាំសប្តាហ៍ទី០២ ខែកញ្ញា ឆ្នាំ២០១៦

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតគោរពជម្រាបជូន **ឯកឧត្តម រដ្ឋមន្ត្រី** មេត្តាជ្រាបៈ

**១.ស្ថានភាពទឹកភ្លៀងៈ**

គិតមកដល់សប្តាហ៍ទី០២ ខែកញ្ញា ឆ្នាំ២០១៦ នេះ ទូទាំងខេត្តទទួលបានទឹកភ្លៀងជាមធ្យម ៥១២.២៥ មម ក្នុងសប្តាហ៍នេះ មានភ្លៀងធ្លាក់ពីតិចទៅមធ្យមចំនួន ៨៧ឃុំ ក្នុងចំណោម ១០០ ឃុំ-សង្កាត់។

**២.ការបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦-២០១៧ៈ**

ផែនការ ១៧០,០០០ ហ.ត ស្ទូង និង ព្រោះបាន ១៨៥,៣៣៩ ហ.ត ស្មើនឹង ១០៩.០២% នៃផែនការ គឺលើស ឆ្នាំ២០១៥ រយៈពេលដូចគ្នាចំនួន ១១,២៩៤ ហ.ត។ បច្ចុប្បន្នបានច្រូតកាត់ស្រូវដើមរដូវបានចំនួន ៤៦,១៨២ ហ.ត ទទួលទិន្នផលបាន ៤,០៦៦ តោន/ហ.ត និងបរិមាណផល ១៨៧,៧៩៥ តោន ស្មើនឹង ៩៤.៣៣%។

ផ្ទៃដីប៉ះពាល់ដោយគ្រោះរាំងស្ងួត ១៤,៨៩៧ ហ.ត សង្គ្រោះបានចំនួន ១០,១៧៥ ហ.ត តាមរយៈបូម និងទឹក ភ្លៀង(បច្ចុប្បន្នកំពុងបូមសង្គ្រោះបន្តនៅទីតាំងដែលមានប្រភពទឹក)។

អាស្រ័យដូចបានគោរពជំរាបជូនខាងលើ សូម **ឯកឧត្តម** មេត្តាជ្រាបជារបាយការណ៍។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រធានមន្ទីរកសិកម្មខេត្ត**

ញឹម ស្រ៊ន

ចម្លងជូន
អគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម
"ដើម្បីគោរពជូនជ្រាប"